# ក្រុមទី១ ករណីសិក្សា៖“រូបភាពផ្ទាល់ខ្លួនដែលត្រូវបានយកទៅបង្ខូចកេរ្តិ៍ឈ្មោះ”

## ការពិពណ៌នាករណី

លីណា គឺជានិស្សិតសាកលវិទ្យាល័យ និងអ្នកសកម្មក្នុងការងារសង្គម។ នាងប្រើ Facebook, Instagram និង Telegram ជាប្រចាំ ដើម្បីទំនាក់ទំនង និងចូលរួមសកម្មភាពសហគមន៍។

ថ្ងៃមួយ មិត្តភក្តិរបស់នាងបានផ្ញើ Screenshot មកប្រាប់ថា មាន Account Facebook មួយកំពុងចែកចាយរូបភាពរបស់នាង ដោយភ្ជាប់ Caption បែបបង្ខូចកេរ្តិ៍ឈ្មោះ និងបង្កការយល់ច្រឡំ។

គណនីនោះបានប្រើឈ្មោះក្លែងក្លាយ និង Tag មិត្តភក្តិរបស់នាង ព្រមទាំងផ្ញើសារទៅអ្នកដទៃ ដោយអះអាងថា នាងមានទំនាក់ទំនងមិនសមរម្យ។

លីណា មានអារម្មណ៍ភ័យខ្លាច ស្រ្តេស និងចាប់ផ្តើមបិទ Social Media មួយចំនួន។

## ព័ត៌មាន

- Facebook Profile បើក Public
- Friend List មើលឃើញសាធារណៈ
- មិនបានបើក 2FA
- រូបភាពជាច្រើន Public
- Fake Account ប្រើរូបពី Facebook របស់នាង

## ដំណើរការវាយប្រហារ

1. ប្រមូលរូបភាព និងព័ត៌មានពី Profile Public
2. បង្កើត Fake Account
3. បង្ហោះរូបភាព និង Caption បង្ខូច
4. Tag មិត្តភក្តិ និងផ្ញើសារ
5. បង្កការភ័យខ្លាច និងប៉ះពាល់ផ្លូវចិត្ត

## សំណួរពិភាក្សា

- តើព័ត៌មានអ្វីខ្លះត្រូវបានយកទៅប្រើ?
- តើ Fake Account អាចបង្កផលប៉ះពាល់អ្វី?
- តើលីណាគួរធ្វើអ្វីភ្លាមៗ?
- តើមិត្តភក្តិគួរជួយនាងដូចម្តេច?
- តើអ្វីដែល “មិនគួរធ្វើ” ពេលជួយជនរងគ្រោះ?